# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ៤៨/១០ ក្រ២ "ឆ"

ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៣៣

ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ: ៣១១

ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១

-សំណុំរឿងជំនុំជំរះលេខ: ៩១៥

ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ វេលាម៉ោង ៩ និង ០០ នាទីព្រឹក ដោយមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

-លោក [redacted] ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ជាព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៤៣៣ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] **រុណា** ភេទប្រុស អាយុ១៤ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ២០ ខែកុម្ភៈ ឆ្នាំ២០០៧ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី៨ ទីកន្លែងកំណើតនៅ[redacted] ក្រុងព្រះសីហនុ អាសយដ្ឋានបច្ចុប្បន្នមិនពិតប្រាកដ នៅលីវ ឪពុកឈ្មោះ [redacted] ម៉ី (រស់) ម្តាយឈ្មោះ[redacted] បុប្ផា (រស់) ។ **(ក្រៅឃុំ) ដីកាសម្រេចមិនឃុំខ្លួនលេខ ៦៧ ត.៣/២១ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១។**

២.ឈ្មោះ [redacted] **ចាន់** ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ កម្រិតវប្បធម៌ថ្នាក់ទី៤ មានទីកន្លែងកំណើត ខេត្តព្រះសីហនុ ទីលំនៅបច្ចុប្បន្ន ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅលីវ ។ **(គេចខ្លួន)**

ជាប់ចោទពីបទ **ប៉ុនប៉ងក្នុងអំពើលួច** ប្រព្រឹត្តនៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៦ , ៣៦១ នៃក្រមព្រហ្មទណ្ឌ។

### អង្គហេតុនៃរឿងមានដូចតទៅ ៖

កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១៦ និង៣០នាទី នៅចំណុចមុខមហោស្រពចាស់ស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មាន



Scanned with CamScanner

ករណី ប៉ុនប៉ងក្នុងអំពើលួច មួយករណី ប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted] វុណា ភេទប្រុស អាយុ១៤ឆ្នាំ និងឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ២០ឆ្នាំ បានធ្វើសកម្មភាពដោយលួចចូលទៅក្នុងផ្ទះល្វែងមហោស្រពចាស់ប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋតែត្រូវម្ចាស់ផ្ទះឃើញទាន់ក៏ឃាត់ខ្លួនជនសង្ស័យទាំង២នាក់ ប្រគល់ឱ្យសមត្ថកិច្ចយកមកអធិការដ្ឋាននគរបាលក្រុងព្រះសីះនុ ដើម្បីធ្វើការសាកសួរ និងកសាងសំណុំរឿងបញ្ជូនមកតុលាការតាមនីតិវិធី។ ជនសង្ស័យទាំង២នាក់ខាងលើ គឺជាមុខសញ្ញាលួចក្នុងមូលដ្ឋានកន្លងមក។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ២៨៦ អ.យ.ច/២១ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ៦៧៥ អ.យ.ច/២២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ: ៣៨៦ ដ.ស.ស/ឃ/២២ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ ។

## នាពេលសវនាការ

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] វុណា ឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១៤ និង ០០នាទី ខ្លួនបានធ្វើសកម្មភាពមានគ្នា ២នាក់ នៅផ្ទះល្វែងមហាស្រពស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ពីមុនមកខ្លួនពុំធ្លាប់ពាក់ព័ន្ធបទល្មើសអ្វីទេ។ ខ្លួនពិតជាបានធ្វើសកម្មភាពជាមួយឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ២០ឆ្នាំ ពិតប្រាកដមែន។

-ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ ឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៤ និង ៣០នាទី ខ្លួននៅផ្ទះស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ខ្លួនបានធ្វើសកម្មភាពលួចចំនួន ៣ដង ដោយមិនចាំថ្ងៃទេ។ ពេលធ្វើសកម្មភាពនោះ ខ្លួនមានគ្នាចំនួន ៣នាក់គឺ ១.ឈ្មោះ រស្មី ភេទប្រុស, ២.ឈ្មោះ អាខ្មៅ ភេទប្រុស, និង៣.រូបខ្លួន។ ខ្លួនធ្វើសកម្មភាពលើកទី១ នៅផ្ទះល្វែងមហោស្រព, លើកទី២ ខ្លួនធ្វើសកម្មភាពចំនួន២នាក់ នៅក្នុងផ្ទះល្វែងមហោស្រប , លើកទី៣ ខ្លួនធ្វើសកម្មភាពនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជិតហាងលក់សម្លៀកបំពាក់ coco។

-ក្រឡាបញ្ជីអានរបាយការណ៍លេខ ១៧៣ **រ.ប.ក/០២១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១** របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ស្តីពីជនជាប់ចោទឈ្មោះ ម៉ី ចាន់ រត់គេចចេញពីអគារ អាស៊ីបូទិច កន្លែងធ្វើចត្តាឡីស័ក។ តាមរបាយការណ៍បានបញ្ជាក់ថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១៦ និង៣០នាទី នៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីប៉ុនប៉ងលួចមួយកើតឡើងបង្កដោយជនសង្ស័យចំនួន២នាក់ ៖

១.ឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៨ឆ្នាំ មុខរបរ និងទីលំនៅមិនពិតប្រាកដ។

២.ឈ្មោះ [redacted] វុណា ភេទប្រុស អាយុ១៤ឆ្នាំ មុខរបរ និងទីលំនៅមិនពិតប្រាកដ។

ក្រោយពេលកើតហេតុកម្លាំងជំនាញអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅសាលាដំបូងខេត្តព្រះសីហនុ។ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ កម្លាំងជំនាញបានយកជនសង្ស័យឈ្មោះ [redacted] ចាន់ និងឈ្មោះ [redacted] វុណា ទៅធ្វើតេស្តរកមេរោគ កូវីដ១៩ ឃើញមានលើឈ្មោះ [redacted] ចាន់ (ម៉ី វុណា គ្មានមេរោគទេ) ក្រោយមកលោកចៅក្រម [redacted] បានចេញ ដីកាបង្គាប់ឱ្យឃុំខ្លួន បន្ទាប់ពីទទួលដីកាឃុំខ្លួន កម្លាំងខ្លួនបានយកទៅឱ្យពន្ធនាគារខេត្តព្រះសីហនុ រីឯឈ្មោះ [redacted] ចាន់ ខាងមន្ទីរសុខាភិបាលដឹកយកទៅព្យាបាលនៅអាគារអាស៊ីបូទិច រហូតដល់ព្រឹកថ្ងៃទី



Scanned with CamScanner

២០ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១១ និង៣០នាទី ឈ្មោះ [redacted] ចាន់ បានរត់គេចខ្លួនតាមដំបូលអាគារផ្ដោះ ទៅអាគារម្ខាងទៀតដែលជាប់គ្នាកំពុងសាងសង់ បាត់តែម្ដង។ តាមការបំភ្លឺរបស់ឈ្មោះ [redacted] ឆាយឡុង ភេទប្រុស អាយុ៣០ឆ្នាំ មុខរបរអ្នកគ្រប់គ្រងមុខសញ្ញាជំងឺកូវីដ១៩នៅក្នុងអាគារអាស៊ីប៉ូទិក បានឱ្យដឹងថា កាលពីវេលាម៉ោង៧ និង០០នាទី ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ ពេលគាត់យកអាហារពេលព្រឹកចែកជូន ពេលនោះឈ្មោះ [redacted] ចាន់ នៅក្នុងបន្ទប់ស្នាក់នៅ លុះដល់វេលាម៉ោង១១និង៣០នាទី ពេលយកអាហារថ្ងៃត្រង់ចែកជូន មិនឃើញឈ្មោះ [redacted] ចាន់ ឡើយ។ ក្នុងពេលនោះកម្លាំងប្រចាំការគោលដៅដើររក តែរកមិនឃើញឡើយ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ និងអំណានលិខិតផ្សេងៗ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៣ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ ឃើញថាជនជាប់ចោទឈ្មោះ [redacted] ចាន់ និងឈ្មោះ [redacted] រុណ ពិតជាបានធ្វើសកម្មភាពប៉ុនប៉ងលួចទ្រព្យសម្បត្តិរបស់គេពិតមែន ហេតុដូចនេះតំណាងសុំតម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៦៧៥ អ.យ.ច/២២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ទុកជាបានការពេញទាំងមូលដដែល និងសុំផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិថា ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រុណ និងអំណានលិខិតផ្សេងៗ ក្នុងសំណុំរឿងឃើញថា កូនក្តីខ្លួនបានឆ្លើយសារភាពអស់ហើយ មិនមានលាក់លៀមអ្វីទេ ហើយកូនក្តីខ្លួនឈ្មោះ [redacted] រុណ ជាអនីតិជន មានអាយុ១៤ឆ្នាំ ជាក្មេងអណាថា ហេតុនេះខ្លួនជាមេធាវីការពារសិទ្ធិ ស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដោយក្តីអនុគ្រោះ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៣៣ ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ មកជំនុំជម្រះ ដែលមានដីកាដំណោះស្រាយលេខ ៣៨៦ ដ.ង.ស/ឃ/២២ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ បានសម្រេចបញ្ជូនជនជាប់ចោទ ១.ឈ្មោះ [redacted] **រុណា** ភេទប្រុស អាយុ១៤ឆ្នាំ កើតឆ្នាំ២០០៧ ជនជាតិខ្មែរ និង២.ឈ្មោះ [redacted] **ចាន់** ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ ពីបទ **ប៉ុនប៉ងក្នុងអំពើលួច** ប្រព្រឹត្តនៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៦ , ៣៦១ នៃក្រមព្រហ្មទណ្ឌ។

**-និយមន័យមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ៖** អំពើលួច គឺជាអំពើដកហូតដោយទុច្ចរិត នូវទ្រព្យសម្បត្តិ ឬ វត្ថុផ្សេងៗ ទៀតរបស់អ្នកដទៃតាមគ្រប់មធ្យោបាយក្នុងគោលបំណង យកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។



Scanned with CamScanner

-និយមន័យមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ទោសដែលត្រូវអនុវត្ត អំពើលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ១.០០០.០០០៛ (មួយលាន) រៀល ទៅ ៦.០០០.០០០៛ (ប្រាំមួយលាន) រៀល។

-និយមន័យមាត្រា ៣៦១ នៃក្រមព្រហ្មទណ្ឌ ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ។

២-តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៧៥ អ.យ.ច/២២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ បានបញ្ជាក់ថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង១៦និង៣០នាទី ស្ថិតនៅចំណុចមុខមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ចាន់ ពិតជាបានប្រព្រឹត្តអំពើ **ប៉ុនប៉ងក្នុងអំពើលួច** ពិតប្រាកដមែន ។

៣-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] វុណ ឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១៤ និង ០០នាទី ខ្លួនបានធ្វើសកម្មភាពមានគ្នា ២នាក់ នៅផ្ទះល្វែងមហាស្រពស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ពីមុនមកខ្លួនពុំធ្លាប់ពាក់ព័ន្ធបទល្មើសអ្វីទេ។ ខ្លួនពិតជាបានធ្វើសកម្មភាពជាមួយឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ២០ឆ្នាំ ពិតប្រាកដមែន។

៤-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ចាន់ ឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៤ និង ៣០នាទី ខ្លួននៅផ្ទះស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ខ្លួនបានធ្វើសកម្មភាពលួចចំនួន ៣ដង ដោយមិនចាំថ្ងៃទេ។ ពេលធ្វើសកម្មភាពនោះ ខ្លួនមានគ្នាចំនួន ៣នាក់គឺ ១.ឈ្មោះ រស្មី ភេទប្រុស, ២.ឈ្មោះ អាខ្មៅ ភេទប្រុស, និង៣.រូបខ្លួន។ ខ្លួនធ្វើសកម្មភាពលើកទី១ នៅផ្ទះល្វែងមហោស្រព, លើកទី២ ខ្លួនធ្វើសកម្មភាពចំនួន២នាក់ នៅក្នុងផ្ទះល្វែងមហោស្រប , លើកទី៣ ខ្លួនធ្វើសកម្មភាពនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជិតហាងលក់សម្លៀកបំពាក់ coco។

៥-តាមអំណានរបាយការណ៍លេខ ១៧៣ រ.ប.ក/០២១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ស្តីពីជនជាប់ចោទឈ្មោះ [redacted] ចាន់ រត់គេចចេញពីអគារ អាស៊ីបូទិច កន្លែងធ្វើចត្តាឡីស័ក។ តាមរបាយការណ៍បានបញ្ជាក់ថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១៦ និង៣០នាទី នៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ មានករណីប៉ុនប៉ងលួចមួយកើតឡើងបង្កដោយជនសង្ស័យចំនួន២នាក់ ៖

១.ឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ១៨ឆ្នាំ មុខរបរ និងទីលំនៅមិនពិតប្រាកដ។

២.ឈ្មោះ [redacted] វុណ ភេទប្រុស អាយុ១៤ឆ្នាំ មុខរបរ និងទីលំនៅមិនពិតប្រាកដ។

ក្រោយពេលកើតហេតុកម្លាំងជំនាញអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានកសាងសំណុំរឿងតាមនីតិវិធីបញ្ជូនទៅសាលាដំបូងខេត្តព្រះសីហនុ។ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១ កម្លាំងជំនាញបានយកជនសង្ស័យឈ្មោះ [redacted] ចាន់ និងឈ្មោះ [redacted] វុណ ទៅធ្វើតេស្តរកមេរោគ កូវីដ១៩ ឃើញមានលើឈ្មោះ [redacted] ចាន់ (ម៉ី វុណ គ្មានមេរោគទេ) ក្រោយមកលោកចៅក្រម [redacted] បានចេញ ដីកាបង្គាប់ឱ្យឃុំខ្លួន បន្ទាប់ពីទទួលដីកាឃុំខ្លួន កម្លាំងខ្លួនបានយកទៅឱ្យពន្ធនាគារខេត្តព្រះសីហនុ រីឯឈ្មោះ [redacted] ចាន់ ខាងមន្ទីរសុខាភិបាលដឹកយកទៅព្យាបាលនៅអាគារអាស៊ីបូទិច រហូតដល់ព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ១១ និង៣០នាទី ឈ្មោះ [redacted] ចាន់ បានរត់គេចខ្លួនតាមដំបូលអាគារផ្ដោះ ទៅអាគារម្ខាងទៀតដែលជាប់គ្នាកំពុងសាងសង់ បាត់តែម្តង។ តាមការបំភ្លឺរបស់ឈ្មោះ [redacted] ឆាយឡុង ភេទប្រុស អាយុ៣០ឆ្នាំ



Scanned with CamScanner

មុខរបរអ្នកគ្រប់គ្រងមុខសញ្ញាជំងឺកូវីដ១៩នៅក្នុងអាគារអាស៊ីបូទិក បានឱ្យដឹងថា កាលពីវេលាម៉ោង៧ និង០០នាទី ថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០២១ ពេលគាត់យកអាហារពេលព្រឹកចែកជូន ពេលនោះឈ្មោះ [redacted] ចាន់ នៅក្នុងបន្ទប់ស្នាក់នៅ លុះដល់វេលាម៉ោង១១និង៣០នាទី ពេលយកអាហារថ្ងៃត្រង់ចែកជូន មិនឃើញឈ្មោះ [redacted] ចាន់ ឡើយ។ ក្នុងពេលនោះកម្លាំងប្រចាំការគោលដៅដើររក តែរកមិនឃើញឡើយ។

៦-តាមអំណានចម្លើយសារភាពរបស់ជនជាប់ចោទ និងភស្តុតាងនានាក្នុងសំណុំរឿងមានលក្ខណៈស៊ីសង្វាក់ជាមួយរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌បានបង្ហាញឱ្យឃើញថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ ស្ថិតនៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជនជាប់ចោទឈ្មោះ [redacted]រុណ ភេទប្រុស អាយុ១៤ឆ្នាំ កើតឆ្នាំ២០០៧ និងឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០១ ពិតជាបានប្រព្រឹត្តអំពើប៉ុនប៉ងលួច ពិតប្រាកដមែន។ ជនជាប់ចោទបានធ្វើសកម្មភាពចូលទៅក្នុងផ្ទះល្វែងរបស់ជនរងគ្រោះ គោលបំណងលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ប៉ុន្តែខណៈពេលនោះត្រូវបានជនរងគ្រោះឃើញទាន់ ហើយបានចាប់ឃាត់ខ្លួនជនជាប់ចោទប្រគល់ឱ្យសមត្ថកិច្ចតែម្តង។ ជនជាប់ចោទឈ្មោះ [redacted] រុណ បានឆ្លើយថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១៤ និង ០០នាទី ខ្លួនបានធ្វើសកម្មភាពមានគ្នា ២នាក់ នៅផ្ទះល្វែងមហាស្រពស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ។ ពីមុនមកខ្លួនពុំធ្លាប់ពាក់ព័ន្ធបទល្មើសអ្វីទេ។ ខ្លួនពិតជាបានធ្វើសកម្មភាពជាមួយឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ២០ឆ្នាំ ពិតប្រាកដមែន។ ជនជាប់ចោទឈ្មោះ [redacted] ចាន់ បានឆ្លើយថា កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៤ និង ៣០នាទី ខ្លួននៅផ្ទះស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ខ្លួនបានធ្វើសកម្មភាពលួចចំនួន ៣ដង ដោយមិនចាំថ្ងៃទេ។ ពេលធ្វើសកម្មភាពនោះ ខ្លួនមានគ្នាចំនួន ៣នាក់គឺ ១.ឈ្មោះ វស្សី ភេទប្រុស, ២.ឈ្មោះ អាខ្មៅ ភេទប្រុស, និង៣.រូបខ្លួន។ ខ្លួនធ្វើសកម្មភាពលើកទី១ នៅផ្ទះល្វែងមហោស្រព, លើកទី២ ខ្លួនធ្វើសកម្មភាពចំនួន២នាក់ នៅក្នុងផ្ទះល្វែងមហោស្រប , លើកទី៣ ខ្លួនធ្វើសកម្មភាពនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ជិតហាងលក់សម្លៀកបំពាក់ coco។ ផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទបានឱ្យឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទគឺជាធាតុផ្សំនៃបទ **ប៉ុនប៉ងក្នុងអំពើលួច** បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, ៣៥៦, ៣៦១ នៃក្រមព្រហ្មទណ្ឌ។

៧-អំពើ និង សកម្មភាពរបស់ជនជាប់ចោទបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់សន្តិសុខរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។

៨-ពេលធ្វើសកម្មភាពប្រព្រឹត្តបទល្មើស ជនជាប់ចោទមានសតិបញ្ញាស្មារតីគ្រប់គ្រាន់ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចតាមបំណងរបស់ខ្លួនហើយជនជាប់ចោទជានីតិជន និងជាអនីតិជន ដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត។

៩-ជនជាប់ចោទឈ្មោះ [redacted] **ចាន់** ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ បានរត់គេចខ្លួនបាត់ ក្នុងអំឡុងពេលធ្វើចត្តាឡីស័ក (ជម្ងឺ កូវីដ១៩) គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើឈ្មោះ [redacted] **ចាន់** ។

១០-តំណាងអយ្យការប្តឹងសុំតម្កល់ការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានស្ថាពរលេខ ៦៧៥ អ.យ.ច/២២ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២២ ទុកជាបានការដដែល និងសុំតុលាការផ្តន្ទាទោសជនជាប់ចោទ។ ចំណុចនេះ គប្បីតុលាការធ្វើការពិចារណា និងសម្រេចតាមការប្តឹងសុំ។

១១.មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទ ៖

១/.ឈ្មោះ [redacted] **រុណ** ភេទប្រុស អាយុ១៤ឆ្នាំ ថ្ងៃខែឆ្នាំកំណើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៧ ជនជាតិខ្មែរ



Scanned with CamScanner

២/.ឈ្មោះ [redacted] **ចាន់** ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ

ជាប់ចោទពីបទ **ប៉ុនប៉ងក្នុងអំពើលួច** ប្រព្រឹត្តនៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៦ , ៣៦១ នៃក្រមព្រហ្មទណ្ឌ។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសជនជាប់ចោទ ៖

១/.ឈ្មោះ [redacted]**រុណា** ភេទប្រុស អាយុ១៤ឆ្នាំ ថ្ងៃខែឆ្នាំកំណើត ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន **៦** (**ប្រាំមួយ**) **ខែ** តែទោសនេះត្រូវអនុវត្តទោសព្យួរធម្មតា ពីបទ **ប៉ុនប៉ងក្នុងអំពើលួច** ប្រព្រឹត្តនៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៦ , ៣៦១ នៃក្រមព្រហ្មទណ្ឌ។

២/.ឈ្មោះ [redacted] **ចាន់** ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ ដាក់ពន្ធនាគារចំនួន **១** (**មួយ**) **ឆ្នាំ** ពីបទ **ប៉ុនប៉ងក្នុងអំពើលួច** ប្រព្រឹត្តនៅចំណុចមហោស្រពចាស់ ក្រុមទី៤ ភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ , ៣៥៦ , ៣៦១ នៃក្រមព្រហ្មទណ្ឌ។

៣-បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] **ចាន់** ភេទប្រុស អាយុ២០ឆ្នាំ កើតឆ្នាំ២០០១ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ។

**២**-សាលក្រមនេះជំនុំជម្រះជាអសាធារណៈនាថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]រុណា និងឈ្មោះ [redacted] ចាន់ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ និងប្រកាសជាអសាធារណៈនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣។

ទុកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា៖ | ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា និងត្រា៖ |

[redacted]

---

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃពុធ ៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

ខេត្តព្រះសីហនុ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner